ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង
ខេត្តបន្ទាយមានជ័យ

សាលក្រមព្រហ្មទណ្ឌលេខ ០១"ត"/០២
ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២២

សំណុំរឿងព្រហ្មទណ្ឌលេខ ២៦០
ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១

សំណុំរឿងជំនុំជម្រះលេខ ២៨៨
ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

# សាលក្រម
# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការទី២ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ។

-កាលបរិច្ឆេទបើកសវនាការ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២១។

-កាលបរិច្ឆេទប្រកាសសាលក្រម ថ្ងៃទី៦ ខែមករា ឆ្នាំ២០២២។

## ក្រុមប្រឹក្សាជំនុំជម្រះ

ឯកឧត្តម [redacted] ឋានៈប្រធានសាលាដំបូង ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា

លោក [redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ឋានៈព្រះរាជអាជ្ញារង

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ឋានៈក្រឡាបញ្ជី

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ២៦០ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

១/-ឈ្មោះ [redacted] ឡា ភេទប្រុស ឆ្នាំកំណើត១៩៨៣ ជនជាតិខ្មែរ ទីកន្លែងកំណើតជំនុំសាវផាង ប្រទេសថៃ។ អាសយដ្ឋានមុនពេលចាប់ខ្លួន[redacted] ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ មុខរបរ កសិករ។ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ[redacted]មានកូន ៥នាក់។ កំរិតវប្បធម៌ថ្នាក់ទី៦។ ទោសពីមុន គ្មាន។

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២០០ ព្រទ.III"ច"/២១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១។

ជាប់ចោទពីបទ : ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។ ប្រព្រឹត្ត នៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣

Scanned with CamScanner

កថាខណ្ឌ៥ ចំណុច៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២/-ឈ្មោះ [redacted]ម៉ុំ ភេទស្រី ថ្ងៃ ខែ ឆ្នាំកំណើតទី៩ ខែមិថុនា ឆ្នាំ១៩៧៨ ជនជាតិខ្មែរ ទីកន្លែងកំណើត ភូមិទោលថ្ម ឃុំទោលថ្ម ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ អាសយដ្ឋានបច្ចុប្បន្ន[redacted] គោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្តីឈ្មោះ [redacted]។ (គេចខ្លួន)។

ជាប់ចោទពីបទ : ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។ ប្រព្រឹត្តនៅភូមិរល្ហីប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

តាមដីកាដំណោះស្រាយលេខ ១៦៨៨ ពស.ព្រស"ង.២"/២១ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តបន្ទាយមានជ័យ។

**មេធាវី [redacted]ណេត ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឡា។**

**<u>អង្គហេតុចោទប្រកាន់មានដូចតទៅ</u>** :

កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាល គោករមៀត បានធ្វើការបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចភូមិរល្ហីប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ឃាត់ខ្លួនឈ្មោះ [redacted] ឡា ដកហូតបានថ្នាំញៀនម៉ាទឹកកកមួយថង់ទម្ងន់ ៤៦.៣០ក្រាម និងថ្នាំញៀនគ្រាប់ចំនួនមួយគ្រាប់។ ឈ្មោះ [redacted] ឡា បានឆ្លើយសារភាពថា : បានទិញថ្នាំញៀនពីឈ្មោះ ធី ឈ្មោះ រី និងឈ្មោះ [redacted]ម៉ុំ យកមកប្រើប្រាស់ និងលក់បន្ត។

<u>កិច្ចពិភាក្សាដេញដោលនាសវនាការ</u> :

-បានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ឡា។

-បានស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] សុភា។

-បានស្តាប់ចម្លើយសាក្សីឈ្មោះ [redacted]ហួន។

-បានស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] ប៉ាន់។

-បានស្តាប់អំណានចម្លើយសាក្សីឈ្មោះ [redacted] សំរេច។

-បានស្តាប់អំណានចម្លើយសាក្សីឈ្មោះ [redacted]រ៉េត។

-បានស្តាប់អំណានចម្លើយសាក្សីឈ្មោះ [redacted]ហួរ។

-បានពិនិត្យភស្តុតាង , របាយការណ៍ឯកសារ និងកំណត់ហេតុផ្សេងទៀត។

<u>សិទ្ធិនិយាយស្តីកត់សម្គាល់របស់ភាគី</u> :

ជនជាប់ចោទឈ្មោះ [redacted] ឡា បានធ្វើការកត់សម្គាល់ថា : ខ្លួនទទួលស្គាល់ថាបានទិញថ្នាំញៀនប្រភេទគ្រាប់ចំនួនពីរគ្រាប់តម្លៃ ២០.០០០រៀល ពីឈ្មោះ [redacted]ម៉ុំ យកមកប្រើប្រាស់។ ថ្នាំញៀនដែលខ្លួនបានទិញ

ចំនួនពីរគ្រាប់នេះ គឺខ្លួនប្រើប្រាស់អស់ចំនួន ០១គ្រាប់ ចំណែកថ្នាំញៀនមួយគ្រាប់នៅសល់ខ្លួនបានបោះចោល ហើយត្រូវបានសមត្ថកិច្ចរកឃើញ។ ចំណែកថ្នាំញៀនដែលសមត្ថកិច្ចបានដកហូតនៅកន្លែងបោកអ៊ុតពុំមែនជារបស់ខ្លួនទេ។ ខ្លួនពុំបានជួញដូរថ្នាំញៀនទេ គឺបានតែប្រើប្រាស់ថ្នាំញៀនប៉ុណ្ណោះ។

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងប្តឹងសុំថា : ក្រោយពីបានពិនិត្យសំណុំរឿង និងក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការឃើញថា ជនជាប់ចោទបានទទួលស្គាល់ថាបានទិញថ្នាំញៀនប្រភេទគ្រាប់ពីឈ្មោះ [redacted]មុំ ចំនួន ០២គ្រាប់យកមកប្រើប្រាស់ ហើយបានប្រើប្រាស់អស់ចំនួន ០១គ្រាប់ ចំណែកថ្នាំញៀនមួយគ្រាប់នៅសល់ត្រូវសមត្ថកិច្ចដកហូត។ ជនជាប់ចោទបានឆ្លើយបដិសេធថា : ពុំបានលក់ថ្នាំញៀនទេ ហើយថ្នាំញៀនដែលដកហូតនៅកន្លែងបោកអ៊ុតក៏ពុំមែនជារបស់ខ្លួនដែរ។ ចម្លើយដោះសារនេះពុំគួរឱ្យជឿបានទេព្រោះតាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ឡា នៅដំណាក់កាលនគរបាលបានឆ្លើយថា : ខ្លួនបានធ្វើសកម្មភាពលក់ថ្នាំញៀនរយៈពេលកន្លះឆ្នាំមកហើយ។ ថ្នាំញៀនយកមកលក់ គឺខ្លួនទិញពីឈ្មោះ ធី ប្រើប្រាស់ទូរស័ព្ទលេខ [redacted] ហើយមុនចាប់ខ្លួនមួយថ្ងៃខ្លួនបានទាក់ទងទិញថ្នាំញៀនពីឈ្មោះ វី តម្លៃ ៥០០.០០០រៀល ហើយបានយកថ្នាំញៀននេះមកលាក់ទុកក្នុងខោអាវ។ ចម្លើយសារភាពនេះគួរឱ្យជឿបានព្រោះស៊ីសង្វាក់ទៅនឹងចម្លើយសាក្សីឈ្មោះ [redacted]ហួរ ដែលបានឆ្លើយថា : នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១០ព្រឹកខ្លួនបានជិះម៉ូតូដើរយកខោអាវអ្នកភូមិមកបោកអ៊ុតដូចរាល់ថ្ងៃ ហើយបានទៅយកខោអាវនៅផ្ទះចៃម្នាក់ពុំស្គាល់ឈ្មោះជាកូនប្រសាររបស់ចៃវ៉ាត់ ម្ចាស់លានដំឡូងភូមិវល្លិប្រេង ហើយចៃម្ចាស់ខោអាវនោះបានប្រមូលខោអាវដាក់ចូលក្នុងថង់ខ្មៅធំមួយឱ្យខ្លួន ហើយខ្លួនបានយកថង់ខោអាវនោះមកផ្ទះរបស់ខ្លួន ហើយរើខោអាវចេញពីថង់ខ្មៅនោះដាក់ចូលក្នុងម៉ាស៊ីនបោកអស់ពាក់កណ្តាលក៏បានឃើញ ថង់ដែពណ៌ខ្មៅមួយនៅក្រោមខោអាវក្នុងថង់ខ្មៅនោះ ហើយខ្លួនបានយកថង់ខ្មៅនោះមកដាក់លើគម្របពាងទឹកហើយបើកមើលឃើញមានម្សៅពណ៌ស ច្រកថង់ពណ៌សមួយដុំ និងមានថង់តូចៗពណ៌សជាច្រើន ខ្លួនសង្ស័យថាជាថ្នាំញៀនក៏បានរាយការណ៍ជូនសមត្ថកិច្ចនគរបាលតែម្តង។ តំណាងអយ្យការយល់ឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ឡា និងឈ្មោះ [redacted]មុំ ដូចការចោទប្រកាន់ ហេតុនេះតំណាងអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងពីរតាមច្បាប់។

មេធាវី [redacted]ណេត ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឡា បានធ្វើសេចក្តីសន្និដ្ឋានការពារថា : ក្រោយពីបានពិនិត្យសំណុំរឿង និងក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការឃើញថា : កូនក្តីនាងខ្ញុំឈ្មោះ [redacted] ឡា គ្រាន់តែបានទិញថ្នាំញៀនចំនួនពីរគ្រាប់ពីឈ្មោះ [redacted]មុំ យកមកប្រើប្រាស់តែប៉ុណ្ណោះ ហើយនៅពេលប្រើប្រាស់មិនអស់នៅសល់មួយគ្រាប់ក៏បោះចោល។ ចំពោះថ្នាំញៀនដែលបានរកឃើញនៅផ្ទះបោកអ៊ុតរបស់ឈ្មោះ [redacted] ហួរ គឺពុំមែនរបស់កូនក្តីនាងខ្ញុំនោះទេ។ នៅថ្ងៃកើតហេតុឈ្មោះ [redacted] ហួរ ហៅ ញ៉ិញ បានជិះម៉ូតូយកខោអាវពីគេជាច្រើនផ្ទះ ហើយពេលយកខោអាវទៅបោកក៏បានឃើញថ្នាំញៀននេះ។ កូនក្តីនាងខ្ញុំពុំបានលក់ដូរថ្នាំញៀនដូចការចោទប្រកាន់ទេ ហើយថ្នាំញៀនដែលដកហូតពីផ្ទះបោកអ៊ុតរបស់ឈ្មោះ [redacted] ហួរ ក៏

Scanned with CamScanner

ពុំមែនជារបស់កូនក្តីនាងខ្ញុំដែរ។ ការចោទប្រកាន់កូនក្តីនាងខ្ញុំថា : បានលក់ថ្នាំញៀនជាវិមតិសង្ស័យ ហេតុនេះ នាងខ្ញុំស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចឲ្យកូនក្តីនាងខ្ញុំឈ្មោះ [redacted] ឡា រួចខ្លួនពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

ជនជាប់ចោទឈ្មោះ [redacted] ឡា បានសំណូមពរថា : សូមតុលាការមេត្តាដោះលែងខ្ញុំបាទដោយមានសេរីភាពវិញ ព្រោះខ្ញុំបាទពុំបានលក់ថ្នាំញៀនទេ។

ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សំអាងហេតុ**

១/-តាមរបាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ឃើញថា : កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ ២០២១ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាល គោករមៀត បានធ្វើការបង្ក្រាបករណី ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចភូមិរល្ហីប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ឃាត់ខ្លួនឈ្មោះ [redacted] ឡា ដកហូតបានថ្នាំញៀនម៉ាទឹកកកមួយថង់ទម្ងន់ ៤៦.៣០ក្រាម និងថ្នាំញៀនគ្រាប់ចំនួនមួយគ្រាប់។ ឈ្មោះ [redacted] ឡា បានឆ្លើយសារភាពថា : បានទិញថ្នាំញៀនពីឈ្មោះ ធី ឈ្មោះ រី និងឈ្មោះ [redacted] មុំ យកមកប្រើប្រាស់ និងលក់បន្ត។

នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ឡា បានឆ្លើយថា : ខ្លួនទទួលស្គាល់ថាបានទិញថ្នាំញៀនប្រភេទគ្រាប់ចំនួនពីរគ្រាប់តម្លៃ ២០.០០០រៀល ពីឈ្មោះ [redacted] មុំ យកមកប្រើប្រាស់។ ថ្នាំញៀនដែលខ្លួនបានទិញចំនួនពីរគ្រាប់នេះ គឺខ្លួនប្រើប្រាស់អស់ចំនួន ០១គ្រាប់ ចំណែកថ្នាំញៀនមួយគ្រាប់នៅសល់ខ្លួនបានបោះចោល ហើយត្រូវបានសមត្ថកិច្ចរកឃើញ។ ចំណែកថ្នាំញៀនដែលសមត្ថកិច្ចបានដកហូតនៅកន្លែងបោកអ៊ុតពុំមែនជារបស់ខ្លួនទេ។ ខ្លួនពុំបានជួញដូរថ្នាំញៀនទេ គឺបានតែប្រើប្រាស់ថ្នាំញៀនប៉ុណ្ណោះ។ ជនជាប់ចោទបានឆ្លើយថា : ពុំបានធ្វើសកម្មភាពលក់ថ្នាំញៀនគឺពុំគួរឲ្យជឿបានទេដោយពុំមានភស្តុតាងមកបញ្ជាក់ ព្រោះតាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ឡា នៅដំណាក់កាលនគរបាលយុត្តិធម៌បានឆ្លើយថា : ខ្លួនបានធ្វើសកម្មភាពលក់ថ្នាំញៀនរយៈពេលកន្លះឆ្នាំមកហើយ។ ថ្នាំញៀនយកមកលក់នេះ គឺខ្លួនទិញពីឈ្មោះ ធី ប្រើប្រាស់ទូរស័ព្ទលេខ [redacted] ហើយមុនចាប់ខ្លួនមួយថ្ងៃខ្លួនបានទាក់ទងទិញថ្នាំញៀនពីឈ្មោះ រី តម្លៃ ៥០០.០០០រៀល ហើយបានយកថ្នាំញៀននេះមកលាក់ទុកក្នុងខោអាវ។ ចម្លើយសារភាពរបស់ជនជាប់ចោទនៅដំណាក់កាលនគរបាលយុត្តិធម៌គួរឲ្យជឿបានព្រោះស៊ីសង្វាក់ទៅនឹងចម្លើយសាក្សីឈ្មោះ [redacted] ហូរ ដែលបានឆ្លើយថា : នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១០ព្រឹកខ្លួនបានជិះម៉ូតូដើរយកខោអាវអ្នកភូមិមកបោកអ៊ុតដូចរាល់ថ្ងៃ ហើយបានទៅយកខោអាវនៅផ្ទះថៃម្នាក់ពុំស្គាល់ឈ្មោះជាកូនប្រសាររបស់ថៃរ៉ាត់ ម្ចាស់លានដំឡូងភូមិរល្ហីប្រេង ហើយថៃម្ចាស់ខោអាវនោះបានប្រមូលខោអាវដាក់ចូលក្នុងថង់ខ្មៅធំមួយឲ្យខ្លួន ហើយខ្លួនបានយកថង់ខោអាវនោះមកផ្ទះរបស់ខ្លួន ហើយរើខោអាវចេញពីថង់ខ្មៅនោះដាក់ចូលក្នុងម៉ាស៊ីនបោកអស់ពាក់កណ្តាលក៏បានឃើញ ថង់ដៃពណ៌ខ្មៅមួយ នៅក្រោមខោអាវក្នុងថង់ខ្មៅនោះ ខ្លួនបានយកថង់ខ្មៅនោះមកដាក់លើគម្របពាងទឹកហើយបើកមើលឃើញមាន

Scanned with CamScanner

ម្សៅពណ៌ស ច្រកថង់ពណ៌សមួយដុំ និងមានថង់តូចៗពណ៌សជាច្រើន ខ្លួនសង្ស័យថាជាថ្នាំញៀនក៏បានរាយការណ៍ជូនសមត្ថកិច្ចនគរបាលតែម្តង។ និងស៊ីសង្វាក់ទៅនឹងចម្លើយលោក [redacted] និងលោក [redacted] សំរេច ជាមន្ត្រីនគរបាលយុត្តិធម៌ដែលបានឆ្លើយបំភ្លឺប្រហាក់ប្រហែលគ្នាថា : ក្រោយពីទទួលបានព័ត៌មានពីឈ្មោះ [redacted] ហួរ ភ្លាមកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាល គោករមៀត បានចុះទៅដល់ផ្ទះរបស់ឈ្មោះ [redacted] ហួរ ពិនិត្យឃើញថា ពិតជាថ្នាំញៀនម៉ាទឹកកកប្រាកដមែនក៏បានយកថ្នាំញៀននេះមកប៉ុស្តិ៍នគរបាលរដ្ឋបាល ហើយបានចាត់តាំងកម្លាំងទៅនាំឈ្មោះ [redacted] ឡា ពីផ្ទះរបស់គាត់មកប៉ុស្តិ៍ ហើយកម្លាំងមួយចំនួនទៀតបានឆែកឆេរផ្ទះរបស់ឈ្មោះ [redacted] ឡា រកឃើញ ថ្នាំញៀនម៉ាទឹកកកចំនួនមួយគ្រាប់នៅក្នុងបរិវេណផ្ទះរបស់ឈ្មោះ [redacted] ឡា។

២/-តាមលទ្ធផលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយសាក្សីឈ្មោះ [redacted] ហួរ ស៊ីសង្វាក់គ្នា និងស៊ីសង្វាក់ទៅនឹងកំណត់ហេតុឆែកឆេរលំនៅដ្ឋាន, កំណត់ហេតុចាប់យកវត្ថុតាងពីជនជាប់ចោទ និងកំណត់ហេតុធ្វើតេស្តរកសារធាតុញៀនលើជនជាប់ចោទឈ្មោះ [redacted] ឡា អាចបញ្ជាក់បានថា ៖ ជនជាប់ចោទឈ្មោះ [redacted] ឡា ពិតជាបានទិញថ្នាំញៀនប្រភេទគ្រាប់ពីឈ្មោះ [redacted] យកមកប្រើប្រាស់ និងបានទិញថ្នាំញៀនម៉ាទឹកកកពីឈ្មោះ ធី ប្រើប្រាស់ទូរស័ព្ទលេខ [redacted] យកមកលក់រយៈពេលកន្លះឆ្នាំមកហើយ ហើយនៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ [redacted]ឡា បានទិញថ្នាំញៀនម៉ាទឹកកកពីឈ្មោះ វី តម្លៃ ៥០០.០០០រៀល បានថ្នាំញៀនម៉ាទឹកកកចំនួនមួយថង់មានទម្ងន់ ៤៦.៣០ក្រាម ហើយយកមកលាក់ទុកក្នុងខោអាវប្រឡាក់របស់ជនជាប់ចោទ ហើយនៅពេលជនជាប់ចោទយកខោអាវនេះទៅបោកអ៊ុត ក៏ត្រូវបានសាក្សីឈ្មោះ [redacted]ហួរ ឃើញរាយការណ៍ជូនសមត្ថកិច្ច។ អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ឡា ជាការទិញថ្នាំញៀនយកមកលក់ និងដើម្បីប្រើប្រាស់ដោយគ្មានការអនុញ្ញាត។ នាំឱ្យកំណត់បានថាអំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ឡា ជាបទល្មើស : ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៥ ចំណុច៦ និងមាត្រា ៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ និងអំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ជាបទល្មើស : ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៣១៧០២/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបញ្ជាក់ថា : សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅថ្លាឈ្មោះ មេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធ ៧៤,៤៧% នៃទម្ងន់សរុប វាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

-ជនជាប់ចោទស្ថិតនៅក្នុងវ័យដែលតុលាការអាចប្រកាសទោសព្រហ្មទណ្ឌបាន។ ដោយអំពើប្រព្រឹត្តរបស់ជនជាប់ចោទបង្ហាញថា : ជនជាប់ចោទមានស្មារតីដឹងខុសត្រូវ និងបានប្រព្រឹត្តអំពើល្មើសដោយមានចេតនាពិតប្រាកដ។

Scanned with CamScanner

មានពិរុទ្ធភាពលើជនជាប់ចោទ :

-ឈ្មោះ [redacted] ឡា ពីបទ : ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។ ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៥ ចំណុច៦ និងមាត្រា ៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ឈ្មោះ [redacted]មុំ ពីបទ : ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។ ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣/-ជនជាប់ចោទឈ្មោះ[redacted]មុំ ត្រូវបានតុលាការរកឃើញពិរុទ្ធភាពពីបទល្មើសដែលនឹងត្រូវធ្វើការប្រកាសទោសលើសពី ១ឆ្នាំ ដោយគ្មានការព្យួរទោស និងផ្អែកលើភស្តុតាងពិរុទ្ធភាពគ្រប់គ្រាន់។ ជនជាប់ចោទឈ្មោះ [redacted]មុំ អវត្តមាននាពេលសវនាការ ហេតុនេះគប្បីតុលាការសម្រេចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted]មុំ និងយកមកឃុំខ្លួនក្នុងពន្ធនាគារតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤/-វត្ថុចាប់យកមាន : ម្សៅក្រាមពណ៌សថ្លាទម្ងន់ ៤៦,៣០ក្រាម (ទម្ងន់ ៤,១៧ក្រាម បានបញ្ជូនទៅធ្វើកោសលវិច័យ) មានបរិមាណសុទ្ធ ៣៤,៤៧ក្រាម និងទូរស័ព្ទដៃចំនួនមួយគ្រឿងម៉ាក Vfone ពណ៌ក្រហម ពិតជាថ្នាំញៀន និងជាវត្ថុតាងសម្ភារៈដែលបានប្រើប្រាស់ក្នុងអំពើល្មើស គប្បីសម្រេចប្រកាសទោសបន្ថែមរឹបអូសយោងតាមបទបញ្ញត្តិមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## សេចក្តីសម្រេច

១/-ផ្តន្ទាទោស :

ក/-ឈ្មោះ [redacted]ឡា ភេទប្រុស ឆ្នាំកំណើត១៩៨៣ ជនជាតិខ្មែរ ទីកន្លែងកំណើតជំនុំសារដាង ប្រទេសថៃ។ អាសយដ្ឋានមុនពេលចាប់ខ្លួន[redacted]ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ មុខរបរ កសិករ។ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ៥នាក់។ កំរិតវប្បធម៌ថ្នាក់ទី៦។ ទោសពីមុន គ្មាន។

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២០០ ព្រទ.III"ច"/២១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១។

*ដាក់ពន្ធនាគារកំណត់រយៈពេល ៥(ប្រាំ)ឆ្នាំ ដោយទោសនេះឲ្យអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល ៤(បួន)ឆ្នាំ ទោសនៅសល់ពីនេះឲ្យព្យួរការអនុវត្តធម្មតាតាមមាត្រា ១០៤-១០៨ នៃក្រមព្រហ្មទណ្ឌ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០(ដប់លាន)រៀល។*

ពីបទ : ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។ ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៥ ចំណុច៦ និងមាត្រា ៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពី

Scanned with CamScanner

ការត្រួតពិនិត្យគ្រឿងញៀន។

ខ/-ឈ្មោះ [redacted] ភេទស្រី ថ្ងៃ ខែ ឆ្នាំកំណើតទី៩ ខែមិថុនា ឆ្នាំ១៩៧៨ ជនជាតិខ្មែរ ទីកន្លែងកំណើត ភូមិទោលថ្ម ឃុំទោលថ្ម ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ អាសយដ្ឋានបច្ចុប្បន្នភូមិ[redacted] គោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្តីឈ្មោះ [redacted]។ (គេចខ្លួន)។

*ដាក់ពន្ធនាគារកំណត់រយៈពេល ៤(បួន)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០(បួនលាន)រៀល។*

ពីបទ : ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។ ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២/-ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] និងយកមកឃុំខ្លួនក្នុងពន្ធនាគារតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣/-<u>រឹបអូស</u> : ម្សៅក្រាមពណ៌សថ្លាទម្ងន់ ៤៦,៣០ក្រាម (ទម្ងន់ ៤,១៧ក្រាម បានបញ្ជូនទៅធ្វើកោសលវិច័យ) មានបរិមាណសុទ្ធ ៣៤,៤៧ក្រាម និងទូរស័ព្ទដៃចំនួនមួយគ្រឿងម៉ាក Vfone ពណ៌ក្រហម។

"វត្ថុចាប់យកទាំងនេះ ត្រូវបានរក្សាទុកដោយមន្ត្រីលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តបន្ទាយមានជ័យ តាមកំណត់ហេតុទទួលវត្ថុតាងលេខ ១១៩ អ.យ.គ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១"។

៤/-សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] កំបាំងមុខជនជាប់ចោទឈ្មោះ [redacted]។

*-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕*

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

*បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។*

*ថ្ងៃព្រហស្បតិ៍ ៤កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥*

*បន្ទាយមានជ័យ, ថ្ងៃទី៦ ខែមករា ឆ្នាំ២០២២*

*បានឃើញ*

*ប្រធានក្រុមប្រឹក្សាជំនុំជម្រះ*

[redacted]

*ក្រឡាបញ្ជី*

[redacted]

Scanned with CamScanner